Khmer

# គ្រឿងញៀនៈ ហេតុការណ៍ដ៏ពិត

## ECSTASY (អិក្សថាស៊ី)

*[E (អ៊ី), Ex (អិក្ស), E n C (អ៊ី អិន ស៊ី), eccy (អិក្សី), MDMA (អឹមឌីអឹមអេ), XTC (អិក្សធីស៊ី), eggs (អេក្ស៍/ស៊ុត), pingers (ភីនជើរ), disco biscuits (ឌិប៊ីសស្គីតឌីស្កូ), pills (ភៀល/ថ្នាំគ្រាប់)]*



*Ecstasy គឺជាឈ្មោះទូទៅដែលគេប្រើនៅតាមផ្លូវ យោងទៅសារធាតុ Methylenedioxymethamphetamine (មីធីលីនីដាយអុក្ស៊ីមេអំហ្វីថាមីន) (MDMA) (អឹមឌីអឹមអេ)។ ជាទូទៅ វាគឺជាគ្រឿងជំរុញទឹកចិត្តដែលមានសារធាតុ hallucinogenic (ហាលូស៊ីណូជីនីក), ecstasy ជាញឹកញាប់វាចេញមកច្រើនតែជាសណ្ឋានថ្នាំគ្រាប់ (ហេតុនេះហើយទើបវាមានឈ្មោះប្រឌិតហៅក្រៅថា "pills" ឬថ្នាំគ្រាប់) ដែលមានពណ៌ចម្រុះផ្សេងៗគ្នាដោយ "រូបត្រា"។ ជាទូទៅ E សំរាប់លេប ហើយក៏អាចកិនឲ្យល្អិត ឬហឹតស្រូបតាមច្រមុះផងដែរ។*

## ឥទ្ធិពលដែលវាបណ្តាលឲ្យកើតមានឡើងៈ

គ្រឿងជំរុញទឹកចិត្តដែលមានក្នុង ecstasy ធ្វើឲ្យប្រព័ន្ធសរសៃប្រសាទសំខាន់ដើរញាប់ព្រមពេលជាមួយគ្នា ក្នុងខណៈដែលសារធាតុ hallucinogens (ហាលូស៊ីណូជីន) នៅក្នុងគ្រឿងញៀនមានឥទ្ធិពលទៅលើការយល់ដឹង។ MDMA កាត់បន្ថយភាពរួញរា ហើយបណ្តាលឲ្យអ្នកប្រើក្លាយទៅជាមានការប្រុងប្រៀបជាមុនការពេញចិត្ត និងមានកម្លាំងច្រើន។ Ecstasy ចាប់ផ្តើម "ល្បួងបញ្ឆោតចិត្ត" ក្នុងរង្វង់ពេល២០នាទីក្រោយពីការប្រើវាដោយធ្វើឲ្យមានអារម្មណ៍អន្ទះអន្ទែង សប្បាយស្រើបស្រាលឡើងដល់កំរិតខ្ពស់បំផុត បន្ទាប់ពីរយៈពេលមួយម៉ោងទៀតក្រោយមក ឬច្រើនជាងនេះ។ ផលប៉ះពាល់នេះអាចមានរយៈពេលដល់ទៅប្រាំបីម៉ោង ទើបបន្ទាប់មកមានការធ្លាក់ចុះវិញ ដែលនាំមកជាមួយនូវការនឿយហត់ និងម៉ួម៉ៅក្តៅក្រហាយ។ ផលប៉ះពាល់ទាំងនេះមានសភាពកាន់តែខ្លាំងក្លាថែមទៀត ប្រសិនបើរួមផ្សំជាមួយគ្រឿងញៀនឯទៀត រួមមានទាំងស្រាផងដែរ។

## រយៈពេលខ្លីៈ

Ecstasy ធ្វើឲ្យឡើងឈាម និងបង្កើនល្បឿនជីពចរ ហើយនិងតម្លើងសីតុណ្ហភាពរបស់រាងកាយ។ អ្នកប្រើគ្រឿងញៀននេះទៅជាលែងឃ្លានបាយ បែកញើសយ៉ាងច្រើន ហើយថែមទាំងអាចនឹងក្អួតទៀតផង។ អ្នកខ្លះអាចក្តៅខ្លាំង ក្នុងខណៈដែលផលប៉ះពាល់ដូចជាការខាំថ្គាមសង្កៀតធ្មេញដោយអចេតនា និងរន្ធប្រស្រីភ្នែករីកធំ ដែលកើតមានជាទូទៅដោយសារការព្រួយបារម្ភ ដំណើរដេកពុំលក់ក្នុងខណៈដែលកំរិតនៃផលប៉ះពាល់បានធ្លាក់ចុះមកវិញ។ ការប្រើថ្នាំញៀនគ្រាប់ក្នុងបរិយាកាសក្តៅ សើម (ដូចជាការជប់លៀងស្រែកឡូឡា ឬកន្លែងរាំលោតចុះឡើង) អាចនាំឲ្យមានការបាត់បង់ជាតិទឹកក្នុងខ្លួន និងគាំងបេះដូងហើយស្លាប់ ថ្វីដ្បិតតែការនេះកម្រកើតមានក៏ដោយ។ មានករណីល្បីរន្ទឺអំពីមនុស្សបាត់បង់ជាតិទឹកក្នុងខ្លួនហួសកំរិត ហើយទទួលការធ្វើទុក្ខពីការពុលជាតិទឹក ដែលនាំឲ្យខួរក្បាលហើមប៉ោង។

**ផលប៉ះពាល់ និងភាពពុលនៃថ្នាំគ្រាប់នីមួយៗពុំអាចស្មានដឹងជាមុនបានឡើយ ធ្វើឲ្យការប្រើគ្រឿងញៀនហួសកំរិតអាចកើតមានឡើងយ៉ាងពិតប្រាកដ។**

## រយៈពេលវែង៖

ក្នុងពេលដែលយើងពុំទាន់ប្រាកដប្រជានៅឡើយ នៅក្នុងដំណាក់កាលនេះ ភស្តុតាងកើនឡើងបង្ហាញឲ្យដឹងថាការប្រើ ecstasy ម្តងហើយម្តងទៀត នឹងធ្វើឲ្យមានការពុលសរសៃប្រសាទនៅខួរក្បាល។ អ្នកប្រើថ្នាំនេះច្រើនរាយការណ៍មកថា មានរោគសញ្ញានៃដំណើរធ្លាក់ទឹកចិត្ត (ដូចជាល្ហិតល្ហៃ ហើយមានអារម្មណ៍ញាប់ញ័រ) ការថ្លង់ស្មារតីផ្នែកជំនាញថយចុះ និងខ្វះខាតការចងចាំ។ ការនេះកើតមានឡើងដោយសារ serotonin (សារធាតុដែលជាអ្នកបញ្ជូនសញ្ញាទៅសរសៃប្រសាទ) ក្នុងខួរក្បាល ត្រូវបានកាត់បន្ថយដោយសារការប្រើ ecstasy។ ការសិក្សាអំពីសត្វបង្ហាញឲ្យដឹងថាការប្រើអស់សារធាតុ serotonin នេះអាចមានរយៈពេលយូរ (រហូតដល់ទៅបីឆ្នាំ) ហើយអាចជាអចិន្ត្រៃយ៍ទៀតផង។

## លទ្ធផលចុងក្រោយ៖

ដូចគ្នានឹងគ្រឿងញៀនខុសច្បាប់ទាំងឡាយ ដែលផលិតនៅកន្លែងពិសោធន៍លើទីធ្លាក្រោយផ្ទះដែរ ពុំមានមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រួតពិនិត្យគុណភាពរបស់វាឡើយ។ ក្នុងខណៈដែលគ្រឿងផ្សំយ៉ាងសកម្មក្នុង ecstasy សំរាប់ឲ្យទៅជា MDMA នៅក្នុងថ្នាំគ្រាប់ភាគច្រើន ការពិតទៅពុំមានសារធាតុនេះឡើយ។ តើមកពីហេតុអ្វី? នេះដោយព្រោះតែមានការពិបាកក្នុងការរកឲ្យបានសារធាតុគីមី ដែលគេត្រូវការសំរាប់ផលិតគ្រឿងញៀន ហើយនេះគឺជាកលល្បិចដែលនាំគេដាក់លាយបញ្ចូលសារធាតុគីមីជាមួយគ្នា។ អ្នកផលិតថ្នាំគ្រាប់ភាគច្រើន គេច្រើនប្រើគ្រឿងឧបករណ៍ពុំទាន់សម័យ ហើយចូលចិត្តកាត់បន្ថយការចំណាយពេលណាដែលគេអាចធ្វើបាន។

សូមចងចាំក្នុងចិត្តថា ពុំជាអ្វីទេ ទោះបីជាឈ្មួញរបស់លោកអ្នក ឬអ្នកលក់ថ្នាំគ្រាប់ឲ្យលោកអ្នក គេអាចគិត ឬនិយាយអ្វីក៏ដោយ វាជាការសង្ស័យកាន់តែខ្លាំងទៀតដែលថា គេស្គាល់ដើមកំណើតនៃទំនិញនេះប្រាកដមែន ទោះបីជាអ្នកមានគុណសម្បត្តិគ្រប់គ្រាន់ក្តី ក៏គេពិបាកនឹងធានាអះអាងអំពីគុណភាពរបស់គ្រឿងញៀនទាំងនេះដែរ។ ជាទូទៅគេគ្រាន់តែនិយាយឡើងវិញ នូវអ្វីដែលគេត្រូវបានប្រាប់ដោយអ្នកដែលបានផ្តល់ថ្នាំគ្រាប់ទាំងនេះដល់គេប៉ុណ្ណោះ។ អ្វីដែលទាំងអស់នោះមានន័យគឺថាជាជាងទិញបាន MDMA លោកអ្នកទំនងជាទទួលបានភេសជ្ជៈសុរាធ្វើពី methampthetamine និងសារធាតុ hallucinogens ឯទៀតលាយបញ្ចូលគ្នា រួមមានទាំង hallucinogens (ប៉ារ៉ាមេថុកស៊ីអំហ្វេថាមីន (PMA) ផងដែរ។ គ្រឿងផ្សំឯទៀតដែលមានតម្លៃថោក ត្រូវបានប្រើដើម្បីធ្វើឲ្យ ecstasy មានរូបរាងប្លែក អាចរួមមានទាំង caffeine (កាហ្វីន) ketamine (គិតាមីន) (ថ្នាំសំរាប់ចាក់ឲ្យសេះស្ងប់អារម្មណ៍) paracetamol (ប៉ារ៉ាសេតាម៉ុល) និង ibuprofen (អាយប៊ូប្រូហ្វិន) ជាដើម។

**ការស្រូបយកជាតិទឹកចូលក្នុងខ្លួន ចាំបាច់ត្រូវគ្រប់គ្រងឲ្យបានហ្មត់ចត់នៅពេលប្រើ ecstasy – ដោយព្រោះថាការផឹកទឹកច្រើនពេកក៏អាចនាំឲ្យមានគ្រោះថ្នាក់ដូចគ្នានឹងការផឹកទឹកតិចពេកដែរ។**

- PMA – គឺជាគ្រឿងញៀនប្រភេទ amphetamine ដែលមានលក្ខណៈជាគ្រឿងជំរុញទឹកចិត្ត និង hallucinogenic ដែលជួនកាលមានលក់ជាសណ្ឋាន ឬឃើញមាននៅក្នុង ecstasy។ វាមានប្រតិកម្មយឺតជាង ក៏ប៉ុន្តែខ្លាំងជាង MDMA ជាញឹកញាប់ មនុស្សគិតថាថ្នាំគ្រាប់របស់គេគឺជា "គ្រាប់កាំភ្លើងស្អុយ" ហើយក៏លេបគ្រាប់ថ្នាំទីពីរទៀត បន្ទាប់មកគេក៏ជ្រុលប្រើហួសកំរិត (OD)។ មានការស្លាប់មួយចំនួនដែលត្រូវបានគេកត់ត្រាទុកដោយសារហេតុការណ៍នេះ។
- ប្រេងដែលមានឈ្មោះថា safrole (សាហ្វ្រូល) ដែលចំរាញ់ចេញពីឫស សំបក និងផ្លែរបស់រុក្ខជាតិ sassafras (សាស់សាហ្វ្រាស) ត្រូវបានគេយកប្រើដើម្បីផលិតជា MDMA។ ការប្រើ sassafras ទៅក្នុងខ្លួនមនុស្ស ត្រូវបានគេដឹងថាបណ្តាលឲ្យខូចខាតថ្លើមជាអចិន្ត្រៃយ៍ និងកើតជម្ងឺមហារីក។
- ចាប់ពីឆ្នាំ២០០០-២០០៤ ប្រព័ន្ធពត៌មានជាតិផ្នែកស៊ើបអង្កេតករណីមនុស្សស្លាប់ បានកត់ត្រាការស្លាប់ចំនួន១១២ទាក់ទិននឹង ecstasy ដោយគ្រឿងញៀនខ្លួនឯងជាមូលហេតុធំជាងគេ នៃការស្លាប់ក្នុង៤៦ភាគរយនៃករណីទាំងនេះ។
- ប្រជុំរោគសញ្ញានៃសារធាតុ serotonin អាចជាលទ្ធផលបណ្តាលមកពីការប្រើ ecstasy ក្នុងខណៈកំពុងប្រើថ្នាំ antidepressants (ថ្នាំរម្ងាប់ការធ្លាក់ទឹកចិត្ត) ឬបណ្តាលមកពីការប្រើគ្រឿងញៀនហួសកំរិត។ រោគសញ្ញារួមមានទាំងការរំជួលចិត្ត ឈឺក្បាល ច្របូកច្របល់ ដំណើរលោតខុសចង្វាក់បេះដូង កន្ត្រាក់សាច់ដុំ ហើយក្នុងករណីធ្ងន់ធ្ងរបំផុតគឺការភ្លឹក និងការស្លាប់។

# ICE (អៃស្ស/ទឹកកក)

*[meth (ម៉េថ), crystal meth (គ្រីស្តល់ម៉េថ), d-meth (ឌីម៉េថ), shabu (ហ្សាប៊ូ), tina (ទីនណា), glass (ក្លាស/កញ្ចក់)]*



*Ice ជាគ្រឿងញៀនគ្រប់គ្រងតាមផ្លូវយោងសំដៅទៅ crystal methamphetamine hydrochloride (គ្រីស្តលម៉េថអំហ្វីថាមីន ហាយដ្រូក្លរ៉ែដ៍) ដែលឥឡូវនេះមានដល់ទៅ៩០ភាគរយនៃ methamphetamine ទាំងអស់ដែលប៉ូលីសចាប់បានក្នុងប្រទេសអូស្ត្រាលី ចាប់តាំងពីគ្រាពាក់កណ្តាលឆ្នាំ១៩៩០មក។ ជាទូទៅ ថ្នាំនេះមានជាសណ្ឋានម្សៅក្រាម ឬជាក្រាម "rocks" (ថ្ម) គ្មានពណ៌សម្បុរ ice អាចគេប្រើសំរាប់ជក់ ហឺតស្រូប ឬចាក់នឹងម្ជុល។*

## ឥទ្ធិពលដែលវាបណ្តាលឲ្យកើតមានឡើង:

ភាពតានតឹង "កំរិតខ្ពស់" ឬ "អន្ទះអន្ទែង" ដែលបណ្តាលមកពីការប្រើ ice អាចមានរយ:ពេលដល់១២ម៉ោង អាស្រ័យទៅលើចំនួនប៉ុន្មានដងដែលគ្រឿងញៀននេះត្រូវបានគេប្រើ។ អ្នកប្រើមានអារម្មណ៍សប្បាយរីករាយ និងរំភើបស្រើបស្រាល។ គ្រឿងញៀននេះធ្វើការដោយធ្វើឲ្យជន់លិចគ្រឿងទទួលសញ្ញារបស់ខួរក្បាលជាមួយនឹង monoamines (ក្រុមអាមីណូដែលជាអ្នកផ្តល់សញ្ញាទៅឲ្យប្រព័ន្ធសរសៃប្រសាទ)។ ជាមួយនឹងការប្រើវាម្តងហើយម្តងទៀត គ្រឿងទទួលសញ្ញារបស់ខួរក្បាលទាំងនេះត្រូវបានបំផ្លាញខូតខាត ធ្វើឲ្យអ្នកប្រើពុំអាចមានអារម្មណ៍រីករាយទាល់តែសោះ ប្រសិនបើគ្មាន ice ជាបន្ថែមទៀតនោះទេ។ ដូច្នេះហើយ វាប្រភេទថ្នាំធម្មជាតិដែលមានជាតិញៀនកំរិតខ្ពស់ទាំងផ្នែករាងកាយ និងទាំងផ្នែកផ្លូវចិត្ត។

## រយ:ពេលខ្លី:

ធ្វើឲ្យចង្វាក់បេះដូងកើនឡើង ហើយដកដង្ហើមញាប់ ជម្ងឺលើសឈាម បញ្ហាឈាមរត់ ហើយនិងបញ្ហាបេះដូង។ វាបង្កើនកាមតម្រេក ធ្វើឲ្យអ្នកប្រើទំនងជាចូលរួមក្នុងឥរិយាបទផ្លូវភេទ ដែលអាចមានគ្រោះថ្នាក់ដោយបង្កើនការប្រថុយនឹងគ្រោះថ្នាក់នៃការឆ្លងរោគតាមផ្លូវភេទ (STI)។

## រយ:ពេលវែង:

តាមកាលកន្លងមក ice ធ្វើឲ្យមនុស្សឆាប់ចាស់យ៉ាងជាក់ស្តែង។ ការចាក់នឹងម្ជុលបណ្តាលឲ្យមានស្លាកស្នាម បូស ខូចសរសៃឈាម និងបង្កើនលទ្ធភាពមានគ្រោះថ្នាក់នៃធាតុបង្ករជម្ងឺតាមឈាម។ អ្នកប្រើគ្រឿងញៀននេះច្រើនលើសលប់ អាចធ្វើឲ្យខូចធ្មេញ ខូចស្បែក ការទទួលទានអាហារពុំគ្រប់គ្រាន់ កាត់បន្ថយការបំពេញមុខងាររបស់សួត និងការឈឺទូទៅ ការឈឺចាប់ ហើយនិងរមួលក្រពើ។ ក្រៅពីការប្រឈមនឹងគ្រោះថ្នាក់នៃការដាច់សរសៃខួរក្បាល វាបានបង្ហាញឲ្យឃើញនូវការប៉ះពាល់ផ្នែកសុខភាពផ្លូវចិត្ត ការបំពេញមុខងារនៃការយល់ដឹង – ice ធ្វើឲ្យញៀន ធ្វើឲ្យមានជម្ងឺភ័យខ្លាច ឬសង្ស័យខុសធម្មតា ភាពស្រមើស្រមៃ បាត់បង់ការចងចាំ ដេកពុំលក់ ហើយនិងជម្ងឺផ្លូវចិត្តលែងដឹងខុសត្រូវ។

## លទ្ធផលចុងក្រោយ:

Ice គឺជាគ្រឿងញៀនដែលអាក្រក់ជាងគេបំផុតមាននៅទីនោះ។ ចំពោះការប៉ះទង្គិចផ្នែកសង្គមវិញ លទ្ធភាពអាចទទួលបានគ្រឿងញៀនក្លាយទៅជាអាទិភាពទូទៅដ៏លើសលប់សំរាប់អ្នកញៀន ice ហើយជាញឹកញាប់ គេក្លាយទៅជាមនុស្សកំរោល ឃោរឃៅ លែងមានការជិតស្និទ្ធជាមួយគ្រួសារ និងមិត្តភក្តិរបស់គេទៀតហើយ។

- ឧស្ម័នពុលដែលកើតមានឡើងក្នុងពេលផលិត meth (ម៉េថ) រួមមានទាំង hydrogen chloride (ហាយដ្រូជីន ក្លរ៉ៃដ៍), hydrochloric acid (អាស៊ីដ ហាយដ្រូក្លរីក), ammonia (អាំម៉ូនីញ៉ា) និង phosphine (ហ្វូសហ្វីន) – ទាំងអស់នេះសុទ្ធតែពុលខ្លាំងចំពោះមនុស្ស។

# MARIJUANA (CANNABIS)
# ម៉ារីវ៉ាណា (ខាណាប៊ីស)

*[pot (ផត់), grass (ហ្គ្រាស/ស្មៅ), weed (វីដ/រុក្ខជាតិតូចៗឥតប្រយោជន៍), dope (ដូប), reefer (រីហ្វើ), joint (ជ័ញ), spliff (ស្ពីលីវ), ya(r)ndi (យ៉ានឌី), rope (រ៉ូប/ខ្សែពួរ), mull (ម៉ល់), cone (ខូន), skunk (ស្កាំង), bhang (បាហាំង), ganja (កញ្ឆា), hash (ហាស្ហ), chronic (គ្រូនីក/រ៉ាំរ៉ៃ)]*



*រុក្ខជាតិ Cannabis បង្កើតជាផលិតផលបីខុសៗគ្នា។ Marijuana គឺជាស្លឹក និងក្បាលផ្កានៃរុក្ខជាតិញី ហើយមានសារធាតុគីមីដែលមានឥទ្ធិពលលើផ្លូវចិត្ត delta-9 tetrahydrocannabinol (THC) (ឌែលតា-9 តេត្រាហាយដ្រូខាណាប៊ីណូល)។ ដើម Cannabis ក៏ផលិតចេញជា hash ផងដែរដែលមានជាដុំពណ៌តូចៗ (មានពណ៌ផ្សេងៗគ្នាពីពណ៌លឿង ទៅពណ៌ខ្មៅ) និងប្រេង hash។ របៀបប្រើគ្រឿងញៀនដែលគេជួបប្រទះបំផុតក្នុងប្រទេសអូស្ត្រាលីគឺការជក់ស្លឹក និងពន្លកផ្ការុក្ខជាតិហាលស្ងួតដាក់លាយក្នុងបារី ឬក្នុងខ្សៀរដាក់ទឹក។*

## ឥទ្ធិពលដែលវាបណ្តាលឲ្យកើតមានឡើង:

THC ត្រូវបានស្រូបចូលតាមសួត (ឬក្រពះ) ចូលទៅក្នុងចរន្តឈាម ហើយនាំឆ្ពោះទៅខួរក្បាល ដែលនៅទីនោះវាធ្វើឲ្យជោរជន់លិចគ្រឿងទទួលសញ្ញាជាមួយនឹងជាតិគីមីដែលជាចំណីខួរក្បាល។ ជាទូទៅ ការជក់ cannabis ធ្វើឲ្យអ្នកប្រើទទួលបានការសម្រាកបន្ធូរអារម្មណ៍។ វាក៏បង្កើនការឃ្លានម្ហូបអាហារ និយាយភាសាសាមញ្ញដែលគេស្គាល់ថា "មានអារម្មណ៍ឃ្លានអាហារ"។

## រយៈពេលខ្លី:

ពិបាកក្នុងការផ្ចង់ស្មារតី ការសម្របសម្រួលចុះអន់ថយ ភ្នែកឡើងក្រហមខ្លាំង ហើយស្ងួតមាត់។

## រយៈពេលវែង:

ជម្ងឺផ្លូវដង្ហើម ជម្ងឺមហារីកទាក់ទិននឹងការជក់ និងមានចំនួនទឹកកាមតិច ហើយស្ងួម្បីតែទឹកចិត្តដែលជំរុញឲ្យចង់រួមភេទក៏មានកាន់តែទាបដែរ។ ការពឹងផ្អែកតាមផ្លូវចិត្តទៅលើគ្រឿងញៀន នាំឲ្យភាពឆាប់ខឹងកើនឡើង បាត់បង់ការចងចាំ ភាពពុំមានលំនឹងនៃការរំជួលចិត្ត ខ្វះខាតការជម្រុញទឹកចិត្ត ជម្ងឺភ័យខ្លាច ឬសង្ស័យផ្តេសផ្តាស និងការព្រួយបារម្ភ ហើយក៏មានទំនាក់ទំនងភ្ជាប់ទៅនឹងជម្ងឺផ្លូវចិត្តលែងដឹងខុសត្រូវ និង schizophrenia (ជម្ងឺផ្លូវចិត្តធ្ងន់ធ្ងរដែលបំបែកស្មារតី) ក្នុងខ្លួនអ្នកជក់ pot ច្រើនផងដែរ។ អាចមានការជំពាក់ទាក់ទិនផ្នែកសង្គមដូចគ្នានេះដែរ – ដូចជាបញ្ហាទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្តិជាដើម។ ភាពគ្មានការងារធ្វើក៏មានទំនាក់ទំនងភ្ជាប់ដោយផ្ទាល់ទៅនឹងការប្រើ marijuana ហួសកំរិតផងដែរ។

## លទ្ធផលចុងក្រោយ:

ដូចគ្នានឹងទម្រង់នៃការហឺតស្រូបចូលទៅក្នុងដងខ្លួនដែរ អ្វីដែលកើតមកពីការដុតជាតិកាបោន ការជក់ weed ជាពិសេស គឺជាការអាក្រក់ណាស់ដល់សុខភាពរបស់លោកអ្នក។ ហើយដោយសារ ganja ដែលមានលក់សព្វថ្ងៃនេះបានដាំក្នុងទឹក មានភស្តុតាងក្នុងព្រឹត្តិការណ៍ខ្លីៗអំពីភាពខាប់ខ្លាំងនៃជាតិពុលរបស់សារធាតុគីមី ដែលនៅតែមានក្នុងរុក្ខជាតិនៅពេលគេយកមកជក់។

**ការស្រាវជ្រាវបញ្ជាក់ឲ្យឃើញថា បុរសដែលប្រើ cannabis ចំនួនច្រើនមានការពិបាកនៅពេលរួមភេទ ដោយភាគច្រើនពុំមានសមត្ថភាពធ្វើឲ្យបានសម្រេចតាមសេចក្តីពេញចិត្តឡើយ***

*ប្រភព: Anthony Smith – ការសិក្សានៅ La Trobe University (សាកលវិទ្យាល័យ La Trobe)។

## ការប៉ះទង្គិចផ្នែករាងកាយ

អ្នកជក់កញ្ឆារយៈពេលយូរអាចកើតជម្ងឺហឺត រលាកទងសួត មហារីកមាត់ បំពង់ក និងសួត ការថ្លង់ស្មារតីចុះខ្សោយ ខូចខាតស្មារតីចងចាំ ពិបាករៀនសូត្រ ហើយនិងជម្ងឺផ្លូវចិត្ត ដ៏ធ្ងន់ធ្ងរ។

## ផលប៉ះពាល់ផ្នែកសង្គម

អ្នកជក់ marijuana រយៈពេលយូរ ក៏ពុំទំនងជាអាចរៀនចប់វិទ្យាស្ថាន TAFE ឬសាកលវិទ្យាល័យឡើយ ហើយភាពគ្មានការងារធ្វើក៏មានទំនាក់ទំនងភ្ជាប់ផ្ទាល់ទៅនឹងការប្រើ marijuana ហួសកំរិតផងដែរ។ អ្នកប្រើវាក្នុងរយៈពេលយូរ ក៏អាចជួបប្រទះបញ្ហាទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្តិផងដែរ។

## គ្រឿងញៀន និងការបើកបរ

ការស្រាវជ្រាវនៅពេលថ្មីៗ ដែលបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលជាតិទប់ទល់ការពារ និងផ្តល់ពត៌មានអំពី cannabis (NCPIC) បង្ហាញថាការបើកបរក្នុងខណៈកំពុងមានអារម្មណ៍មិនធម្មតាដោយសារការប្រើថ្នាំញៀន អាចបង្កើនលទ្ធភាពឲ្យលោកអ្នកមានគ្រោះថ្នាក់ដល់ទៅ៣០០ភាគរយ។

## Marijuana និងច្បាប់

តើអ្នកកំពុងមានគំនិតរើរវាយអំពីការឈប់សម្រាកនៅតំបន់ត្រូពិក Phuket (ភូខេត) ឬ? សូមទទួលការព្រមានជាមុន: ការផ្តន្ទាទោសដោយសារ marijuana ឬប្រភេទគ្រឿងញៀនណាមួយ អាចធ្វើឲ្យផែនការឈប់សម្រាករបស់លោកអ្នកនៅគាំងដោយគ្មានពេលកំណត់។ "ប្រសិនបើលោកអ្នកទទួលការផ្តន្ទាទោសដោយសារ cannabis ការនេះនឹងហាមឃាត់លោកអ្នកមិនឲ្យធ្វើដំណើរទៅកាន់បណ្តាប្រទេសជាច្រើនទៀត" លោក Dennis Young នាយកប្រតិបត្តិនៃ DRUG ARM នៅទីក្រុង Brisbane មានប្រសាសន៍។ "វាក៏នាំឲ្យប៉ះពាល់ដល់ការជ្រើសរើសសំរាប់សិក្សា និងការងាររបស់លោកអ្នកទៅអនាគតផងដែរ។ មនុស្សជាច្រើនពុំយល់ ឬពុំបានគិតឲ្យដិតដល់អំពីផលវិបាកផ្នែកច្បាប់ក្នុងរយៈពេលយូរអង្វែងឡើយ។"

**ថ្វីបើតាមហេតុការណ៍មានមនុស្សជាច្រើនយល់ថាក្មេងជំទង់ទាំងអស់ គឺជា "អ្នកជក់គ្រឿងញៀន" ក្តី មានជនជាតិអូស្ត្រាលីវ័យក្មេង(១៤-១៩ឆ្នាំ) បួននាក់ ក្នុងចំណោមប្រាំនាក់ ពុំដែលប្រើគ្រឿងញៀនឡើយ******

**ប្រភព: ការស្ទង់មតិអ្នករស់នៅក្នុងផ្ទះសំរាប់យុទ្ធសាស្ត្រជាតិប្រឆាំងនឹងគ្រឿងញៀន (NDSHS) ឆ្នាំ២០០៧។

# COCAINE (ខូខេន)

*[coke (ខូក), snow (ស្នូ/ព្រឹល), Charlie (ឆាលី), crack cocaine (កំទេចខូខេន): crack (ក្រេក), rock (ថ្ម), base (បេស្ស), sugar block (ស្ងហ្គាប្លុក/ដុំស្ករ), freebase (ហ្វ្រីបេស្ស)]*



*Cocaine គឺជាគ្រឿងជំរុញទឹកចិត្តដែលមានសណ្ឋានជាម្សៅពណ៌ស។ ជាទូទៅសម្រាប់ហឺតស្រូប វាក៏សម្រាប់ចាក់នឹងម្ជុល លេប ឬលាបត្រដុសនឹងអញ្ចាញធ្មេញដែរ។*

## ឥទ្ធិពលដែលវាបណ្តាលឲ្យកើតមានឡើង:

គឺអាស្រ័យទៅលើគុណភាព និងភាពសុទ្ធ cocaine ទាំងបីប្រភេទផ្តល់នូវភាពអន្ទះអន្ទែងយ៉ាងតានតឹងក្នុងរយៈពេលខ្លី បណ្តាលមកពីការបញ្ចេញនូវសារធាតុគីមីអ្នកបញ្ជូនសញ្ញាទៅសរសៃប្រសាទ (neurochemical) ហៅថា dopamine (ដូផាមីន)។ ក្រៅអំពីការទទួលអារម្មណ៍រំភើបស្រើបស្រាលខុសពីធម្មតា អ្នកប្រើមានអារម្មណ៍ជឿជាក់ក្នុងចិត្តហួសហេតុ ហើយនិយាយច្រើនទៀតផង។

## រយៈពេលខ្លី:

បង្កើនចង្វាក់បេះដូង ភាពរំជួលចិត្ត ជម្ងឺភ័យខ្លាច ឬសង្ស័យផ្តេសផ្តាស និងភាពស្រមើស្រមៃ កន្ទ្រាក់សាច់ដុំ និងក្អួតចង្អោរ។ ការប្រើ cocaine ជាច្រើនម៉ោង ឬច្រើនថ្ងៃបណ្តាលឲ្យមានការ "បែកខ្ញាត់ខ្ញាយ" (ឧទាហរណ៍ ដំណើរធ្លាក់ទឹកចិត្ត ហើយមានភាពល្ហិតល្ហៃ)។

## រយៈពេលវែង:

ជម្ងឺផ្លូវចិត្តលែងដឹងខុសត្រូវដោយសារ cocaine – បង្ហាញពីចរិកលក្ខណៈឃោរឃៅ ឥរិយាបទកំរោល និងការភាន់ច្រឡំយល់ផ្តេសផ្តាស – ក៏ដូចជាបញ្ហាក្នុងការដេក ការអន់ថយផ្នែកដំណើរផ្លូវភេទ ការដាច់សរសៃខួក្បាល ការប្រកាច់ ហើយនិងខូចក្រលៀនផងដែរ។ ការហឺតស្រូបគ្រឿងញៀន ធ្វើឲ្យខូចដល់ភ្នាសរំអិលស្តើងនៃច្រមុះ ដែលអាចនាំឲ្យបាក់សន្ទះច្រមុះជាយថាហេតុ។ ការចាក់នឹងម្ជុលក៏នឹងបណ្តាលឲ្យខូចដល់ជាលិកាស្បែកដែរ។

## លទ្ធផលចុងក្រោយ:

ទោះបីប្រភពរបស់លោកអ្នកអះអាងពីអ្វីក៏ដោយ ភាពសុទ្ធល្អនៃ coke ក្នុងប្រទេសអូស្ត្រាលីមានកំរិតទាបណាស់ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសមួយចំនួនទៀត ដូច្នេះគ្រឿងញៀនសំរាប់ផ្គត់ផ្គង់ក្នុងតំបន់ត្រូវបាន "កាត់" ពុំខានឡើយ ជាមួយគ្រឿងញៀនឯទៀតដូចជា speed, meth ហើយនិងម្សៅ ecstasy ជាដើម។

**ការរួមផ្សំនៃ cocaine និងស្រា បង្កើតជាសារធាតុគីមីហៅថា cocaethylene (ខូខេអេធីលែន) ដែលពុលខ្លាំងជាងការប្រើគ្រឿងញៀនទាំងនេះណាមួយតែឯង។**

# SPEED (ស្ពីដ៍/ល្បឿន)

*[whiz (វិស្ស), point (ភ័ញ), zip (ហ្ស៊ីប), go-ee (ហ្គោអ៊ី), snow (ស្នូ/ព្រឹល), gas (ហ្គាស/ឧស្ម័ន), pure (ភ្យួរ/សុទ្ធ), eve (អ៊ីវ), gogo (ហ្គោហ្គោ)]*



*Speed គឺជា amphetamine (អំហ្វីថាមីន)។ ជាទូទៅ វាគឺជាម្សៅពណ៌លឿងលាយស/ពណ៌លឿង ក៏ប៉ុន្តែអាចមានពណ៌ផ្កាឈូក ឬពណ៌ត្នោត – ប្រភេទផ្សេងៗគ្នាមានចាប់ពីស្តើងខ្លាំង ទៅដល់គគ្រើមខ្លាំង – ឬជាវត្ថុរាវស្អិតអន្ទឹលក្នុងគ្រាប់ថ្នាំមូលទ្រវែង។ គ្រឿងញៀនអាចសំរាប់លេប ជក់ ហឺតស្រូប ចាក់នឹងម្ជុល ឬដាក់បញ្ចូលតាមគូថ។*

## ឥទ្ធិពលដែលវាបណ្តាលឲ្យកើតមានឡើង:

ដូចគ្នានឹង amphetamines ទាំងអស់ដែរ speed ធ្វើឲ្យមានភាពអន្ទះអន្ទែងយ៉ាងតានតឹងក្រោយពីបានប្រើវា។ បង្កើនកម្លាំង បំបាត់ការឃ្លានបាយ និងភាពរវៀសរវៃគឺជារឿងធម្មតាទេ – ភាគច្រើន ដោយសារគ្រឿងញៀនធ្វើសកម្មភាពបន្ថែមល្បឿនបញ្ជូនសញ្ញារវាងខួរក្បាល និងរាងកាយ។ ដោយហេតុនេះហើយវាបណ្តាលឲ្យការដកដង្ហើម និងចង្វាក់បេះដូងកើនឡើង ក៏ដូចជាសម្ពាធឈាមឡើងខ្ពស់ដូច្នោះដែរ។

## រយៈពេលខ្លី:

បែកញើសច្រើនហួស ឡើងកំដៅហួសហេតុ ស្រវាំងភ្នែក ឈឺក្បាល សង្កៀតធ្មេញ ខាំថ្គាម ឆ្អើមចង់ក្អួត ហើយនិងចុះរាគ។

## រយៈពេលវែង:

ដូចគ្នានឹង ice ដែរ ការប្រើរយៈពេលយូរអង្វែង ធ្វើឲ្យអ្នកប្រើឆាប់ចាស់ច្រើន និងនាំឲ្យធ្មេញអន់ថយ មានបញ្ហាបេះដូង ស្រកទម្ងន់ ដាច់សរសៃខួរក្បាលដ៏ធ្ងន់ធ្ងរ និងប្រឈមគ្រោះថ្នាក់យ៉ាងខ្លាំងពីការញៀន។ ក៏ដូចជាការរងទុក្ខទោសដោយសារការគ្រប់គ្រងសតិអារម្មណ៍ចុះអន់ខ្សោយ អាកប្បកិរិយាដែលភាន់ច្រឡំគំនិត ឬដែលអត់ទ្រាំពុំបាន អ្នកប្រើដែលពឹងផ្អែកទាំងស្រុងទៅលើគ្រឿងញៀន អាចក្លាយទៅជាមនុស្សឃោរឃៅ និងរំលោភបំពាន ហើយគ្រឿងញៀននេះហើយដែលបំផ្លាញគ្រួសារ និងមិត្តភាពជាច្រើន។

## លទ្ធផលចុងក្រោយ:

Speed គឺជាគ្រឿងញៀនដ៏ "ក្រខ្វក់" យ៉ាងពិសេសត្រូវបានគេកាត់ ឬលាយបញ្ចូលជាមួយគ្រឿងញៀនដទៃទៀតមួយចំនួន ថែមទាំងដាក់លាយជាមួយម្សៅសាប៊ូផងដែរដើម្បីបង្កើនប្រាក់ចំណេញ។ ការប្រើគ្រឿងញៀននេះក្នុងរយៈពេលយូរអង្វែង លោកអ្នកមើលទៅឃើញស្គមស្លេកស្លាំង មានស្បែកអាក្រក់ ធ្វើឲ្យធ្មេញរបស់លោកអ្នកខូចអន្តរាយ ហើយអាចក្លាយជាមនុស្សពុំសមហេតុផល កំរោលចូលហើយឃោរឃៅ។

**"ជម្ងឺផ្លូវចិត្តលែងដឹងខុសត្រូវដោយសារគ្រឿងញៀន Speed" មានជាទូទៅជាមួយនឹងការប្រើ amphetamines ហួសកំរិត ហើយមានលក្ខណៈដូចគ្នាបេះបិទនឹងជម្ងឺ paranoid schizophrenia (ជម្ងឺផ្លូវចិត្តធ្ងន់ធ្ងរដែលបំបែកស្មារតី)។**

# GHB (ហ្គីហេជ្ជប៊ី)

*[G (ហ្គី), fantasy (ហ្វែនថាស៊ី/វេរីវាយអស្ចារ្យ), liquid E (លីគ្វិតអ៊ី/វត្ថុរាវ អ៊ី), grievous bodily harm (GBH)/ហ្គីហេជ្ជប៊ី)]*



*Gamma-hydroxybutyrate (ហ្គាំម៉ា-ហាយដ្រូហ្ស៊ីប៊ូថាយរ៉េត) ឬ GHB គឺជាគ្រឿងញៀនដែលជាទូទៅគេតែងជួបប្រទះនៅលើឆាករាំ ហើយជួនកាលយោងសំដៅទៅ ecstasy រាវដោយសារគុណភាពនៃការជំរុញទឹកចិត្ត ធ្វើឲ្យសប្បាយស្រើបស្រាល និងនាំឲ្យមានសម្រើបតណ្ហារបស់វា។ និយាយអំពីសារធាតុគីមីវិញ ទោះជាយ៉ាងណាក្តី គ្រឿងញៀននេះពុំទាក់ទិននឹង MDMA ទាល់តែសោះ។ ដោយមានរសជាតិប្រៃខ្សោយ វាពុំមានពណ៌សម្បុរ និងក្លិនឡើយ។*

## ឥទ្ធិពលដែលវាបណ្តាលឲ្យកើតមានឡើងៈ

ពីដើមដំបូងមក គ្រឿងញៀននេះត្រូវបានគេបង្កើតឡើងសំរាប់ជាថ្នាំស្ពឹកទូទៅ ផលប៉ះពាល់សរុបទាំងអស់គឺជាថ្នាំសម្រួលសាច់ដុំ។ អ្នកប្រើវាត្រូវបានកាត់បន្ថយភាពរួញរា និងការងងុយដេកទូទៅ។ ការប្រើវាលើសកំរិតអាចនាំឲ្យសន្លប់ឥតដឹងខ្លួន ប្រកាច់ និងក្អួតចង្អោរ ពេលលាយវាជាមួយស្រាធ្វើឲ្យមានគ្រោះថ្នាក់ជាពិសេស ហើយអាចនាំឲ្យគាំងប្រដាប់ដកដង្ហើមទាំងមូល បេះដូងឈប់ដើរ និងស្លាប់។ អាក្រក់ជាងនេះទៅទៀត គ្រឿងញៀនអាចធ្វើឲ្យញៀនផ្នែករាងកាយ និងផ្លូវចិត្ត – ការដកថយមកវិញដោយឈប់ប្រើវា បណ្តាលឲ្យដេកពុំលក់ មានការព្រួយបារម្ភ មានប្រតិកម្មទៅនឹងពន្លឺ និងសម្លេងខ្លាំង ហើយនិងការស្ពឹកស្រពន់នៃគំនិតឆ្លើយតប។

## លទ្ធផលចុងក្រោយៈ

ការប្រឈមនឹងគ្រោះថ្នាក់ធំរបស់អ្នកប្រើ GHB គឺការប្រើគ្រឿងញៀនលើសកំរិតដែលនាំឲ្យស្លាប់។ ថ្វីដ្បិតតែមានការធានារ៉ាប់រងពីអ្នកផ្តល់គ្រឿងញៀនក៏ដោយ លោកអ្នកនឹងពុំអាចដឹងថាចំនួនដែលផលិតបានម្តងៗណាមួយ មានការផ្លាស់ប្តូរកម្លាំង ឬការលាយក្នុងទឹកឡើយ ហេតុនេះហើយ ការរកឲ្យដបានឹងជាក់លាក់អំពីអ្វីដែលជាបរិមាណមានសុវត្ថិភាព គឺជាការពិបាកខ្លាំង។ ផលប្រយោជន៍ដែលបានមកពុំសមរម្យនឹងទំហំនៃការប្រឈមនឹងគ្រោះថ្នាក់ឡើយ។

**ពេលដាក់លាយជាមួយស្រា GHB អាចធ្វើឲ្យពុលកាន់តែលឿន – នេះហើយគឺជាមូលហេតុដែលជាញឹកញាប់នាំឲ្យវាទាក់ទិនក្នុង “drink-spiking” (ពេលស្រា ឬគ្រឿងញៀនត្រូវបានគេដាក់លាយក្នុងភេសជ្ជៈដែលអ្នកផឹកពុំបានដឹងខ្លួន)។**

# DEPRESSANTS (ថ្នាំរម្ងាប់ការធ្លាក់ទឹកចិត្ត)

*[benzos (ប៊ីនហ្សូស), tranks (ត្រែង), serries (ស៊ើរីស), mandies (ម៉ែនឌីស), sleepers (ស្លីបភើរ /អ្នកលេ្ងាភនឹងដេក)]*

*ក្រៅពីនេះត្រូវបានគេស្គាល់ថាជា “downers/ថ្នាំដេកលក់” ថ្នាំរម្ងាប់ការធ្លាក់ទឹកចិត្ត មានសកម្មភាពយឺត ឬកាត់បន្ថយការបំពេញមុខការរបស់ខួរក្បាល និងរាងកាយ។ ដោយភាគច្រើនត្រូវបានប្រើជាថ្នាំដែលមានសំបុត្រពេទ្យ គ្រឿងញៀនទាំងនេះក៏បានគេស្គាល់ច្បាស់ថាជាសារធាតុ “ខុសច្បាប់” ឬសារធាតុកែប្រែអារម្មណ៍ ដែលអាចនាំឲ្យកើតមានព្រឹត្តិការណ៍អ្វីមួយចាប់ពីការមានអារម្មណ៍ធូរស្រាល និងការសប្បាយចិត្តល្មម ទៅដល់ការរម្ងាប់ទុក្ខព្រួយ និងការបាត់បង់ស្មារតីទាំងស្រុងក្នុងមួយរយៈពេល។*

## ឥទ្ធិពលដែលវាបណ្តាលឲ្យកើតមានឡើង:

Depressants អាចមានសកម្មភាពដូចជាថ្នាំស្ពឹកសំរាប់ប្រព័ន្ធសរសៃប្រសាទសំខាន់ ដោយកាត់បន្ថយអារម្មណ៍នៃការព្រួយបារម្ភ ការតានតឹងក្នុងចិត្ត ឬការភ័យខ្លាច និងសង្ស័យផ្តេសផ្តាស។ ថ្នាំនេះក៏រម្ងាប់ការដេកពុំលក់ និងធ្វើឲ្យធូរស្រាលដល់សាច់ដុំរាងកាយផងដែរ។ ជាញឹកញាប់ អ្នកប្រើបានរាយការណ៍ឲ្យដឹងថាអារម្មណ៍របស់គេបានប្រសើរឡើង ហើយគេមានអារម្មណ៍អាចចូលរួមកិច្ចការជាមួយអ្នកផងបានច្រើន។ ចំពោះទស្សនីយភាពដែលកើតឡើងដោយគ្រឿងញៀនវិញ ថ្នាំរម្ងាប់ការធ្លាក់ទឹកចិត្ត អាចត្រូវគេប្រើជា “ថ្នាំការពារ” ដែលពុំទាន់ស្ល ប្រើសំរាប់ទប់ទល់នឹងរោគសញ្ញានៃការដកខ្លួនចេញ ឬ “ការធ្លាក់ចុះ” ពីការប្រើគ្រឿងជំរុញទឹកចិត្តខុសច្បាប់ដទៃទៀត។

## រយៈពេលខ្លី:

ការវិលមុខ ការច្រឡូកច្របល់ សំដីឡូល។ ដកដង្ហើមខ្លី ការសម្របសម្រួល និងការវិនិច្ឆ័យចុះខ្សោយ និងសម្ពាធឈាមទាប។ ការចាត់ចែងប្រើថ្នាំរម្ងាប់ការធ្លាក់ទឹកចិត្តដោយខ្លួនឯង ក្នុងខណៈកំពុងឋិតនៅក្រោមឥទ្ធិពលគ្រឿងញៀនដទៃទៀត គឺជាការគ្រោះថ្នាក់ដែលអាចនាំឲ្យមានការឈប់ដកដង្ហើម ឬស្លាប់។

## រយៈពេលវែង:

ថ្នាំរម្ងាប់ការធ្លាក់ទឹកចិត ឬថ្នាំធ្វើឲ្យដេកលក់ជាច្រើនក៏បណ្តាលឲ្យញៀនដែរ ប្រសិនបើប្រើវាជារឿយៗ ហើយរោគសញ្ញាដែលបណ្តាលមកពីការដកខ្លួនចេញឈប់ប្រើថ្នាំទាំងនេះ រួមមានទាំងដំណើរដេកពុំលក់ ភ័យញាប់ញ័រ និងការព្រួយបារម្ភផងដែរ។

## លទ្ធផលចុងក្រោយ:

ថ្នាំញៀនទាំងនេះគឺសំរាប់តែចេញឲ្យប្រើដោយមានសំបុត្រពេទ្យសំរាប់មូលហេតុដ៏ជាក់លាក់ប៉ុណ្ណោះ ហើយពុំមែនយកប្រើដើម្បីដកខ្លួនចេញពីគ្រឿងញៀនឯទៀតនោះឡើយ។ ប្រសិនបើលោកអ្នកប្រើថ្នាំដេកលក់គ្រាន់តែសំរាប់ដកខ្លួនចេញពីគ្រឿងញៀនឯទៀតនោះ វាជាការល្អដោយគ្រាន់តែដេកឲ្យស្វាងជាតិគ្រឿងញៀន នោះគឺជាការស្រេច។ ការប្រើវាច្រើនពេក ឬជាមួយនឹងភេសជ្ជៈលាយថ្នាំញៀនខុស នោះលោកអ្នកប្រឈមនឹងគ្រោះថ្នាក់ដោយការភ្លឹក ឬស្លាប់។

**ដោយការលាយជាមួយស្រា ថ្នាំរម្ងាប់ការធ្លាក់ទឹកចិត្ត ធ្វើឲ្យចង្វាក់ដង្ហើមរបស់លោកអ្នកកាន់តែយឺត រហូតដល់លោកអ្នកអាចឈប់ដកដង្ហើមទៀតផង។**

# តើត្រូវការជំនួយឬ?

សូមកត់ចំណាំថាអង្គការដែលមានចុះដូចតទៅនេះ ប្រហែលជាមានផ្តល់កិច្ចបំរើ និងធនធានជាភាសាអង់គ្លេសតែប៉ុណ្ណោះ។

**NATIONAL DRUGS CAMPAIGN**
**(យុទ្ធនាការជាតិទប់ទល់នឹងគ្រឿងញៀន)**

**1800 250 015** (លេខទូរស័ព្ទឥតគិតថ្លៃ)

**www.australia.gov.au/drugs**

ចំពោះពត៌មានបន្ថែមអំពីយុទ្ធនាការ ឬដើម្បីស្វែងរកឲ្យបានដឹងច្រើនថែមទៀតអំពីពត៌មាន និងកិច្ចបំរើជួយផ្គត់ផ្គង់មាននៅក្នុងរដ្ឋ / ដែនដីរបស់លោកអ្នក។

**ពត៌មានអំពីសុរា**

**www.alcohol.gov.au**

វិបសាយជាតិសំរាប់ពត៌មានអំពីសុរារបស់រដ្ឋាភិបាលអូស្ត្រាលី បង្កើតឡើងដោយក្រសួងសុខាភិបាល និងមនុស្សចាស់។

**មជ្ឈមណ្ឌលជាតិទប់ទល់ការពារ និងផ្តល់ពត៌មានអំពី CANNABIS (NCPIC)**

**1800 304 050** (លេខទូរស័ព្ទឥតគិតថ្លៃ)

**www.ncpic.org.au**

មជ្ឈមណ្ឌលជាតិទប់ទល់ការពារ និងផ្តល់ពត៌មានអំពី Cannabis (NCPIC) មានគោលបំណងកាត់បន្ថយការប្រើ Cannabis ក្នុងប្រទេសអូស្ត្រាលី ដោយការទប់ទល់នឹងការប្រើគ្រឿងញៀន ហើយផ្តល់ភស្តុតាង-សំអាងលើពត៌មាន និងការធ្វើអន្តរាគមន៍ដល់សហគមន៍។

**TED NOFFS FOUNDATION**

**1800 151 045** (លេខទូរស័ព្ទឥតគិតថ្លៃ)

**www.noffs.org.au**

ផ្តល់នូវកិច្ចបំរើដ៏សំខាន់សំរាប់មនុស្សវ័យក្មេង និងគ្រួសាររបស់គេដែលជួបប្រទះនឹងបញ្ហាគ្រឿងញៀន និងសុរា ហើយនិងការប៉ះទង្គិចទាក់ទិននឹងបញ្ហានេះ។

**TURNING POINT**

**1800 888 236** (លេខទូរស័ព្ទឥតគិតថ្លៃ)

**www.turningpoint.org.au**

Turning Point ខិតខំជាខ្លាំងដើម្បីធ្វើឲ្យកើតមាន និងបង្កើនជាអតិបរមានូវសុខភាពល្អ និងសុខមាលភាពរបស់បុគ្គលផ្ទាល់ខ្លួន និងសហគមន៍ដែលរស់នៅជាមួយ ហើយរងឥទ្ធិពលដោយការអន្តរាយទាក់ទិននឹងសុរា និងគ្រឿងញៀនឯទៀត។

**AUSTRALIAN DRUG FOUNDATION (ADF)**
**(មូលនិធិទប់ទល់នឹងគ្រឿងញៀនអូស្ត្រាលី) (ADF)**

**www.adf.org.au**

ផ្តល់ពត៌មានដ៏ទូលំទូលាយអំពីគ្រឿងញៀន មានរាប់បញ្ចូលទាំងការស្រាវជ្រាវចុងក្រោយបំផុត សន្និកពត៌មាន ពត៌មានថ្មីទាន់ពេលនៅក្នុងសន្និសីទ និងសារពត៌មាន គោលនយោបាយរដ្ឋាភិបាល និងអ្វីៗជាច្រើនទៀត។

**បណ្តាញផ្តល់ពត៌មានអំពីគ្រឿងញៀនអូស្ត្រាលី (ADIN)**

**www.adin.com.au**

ADIN ផ្តល់លទ្ធភាពប្រើដ៏ងាយស្រួលតាមរយៈ១២០០វិបសាយដែលបានពិនិត្យមើលឡើងវិញតាមបែបបទវិជ្ជាជីវៈ ហើយតភ្ជាប់ទំនាក់ទំនងទៅទីភ្នាក់ងារផ្នែកគ្រឿងញៀន និងស្រាទាំងឡាយទៀត – ចាប់ពីក្រុមតូចៗក្នុងតំបន់ ទៅដល់អង្គការទូទាំងប្រទេស។

**DRUG ARM**

**1300 656 800**

**www.drugarm.com.au**

DRUG ARM Australasia គឺជាអង្គការក្រៅរដ្ឋាភិបាលពុំគិតផលប្រយោជន៍ផ្ទាល់ខ្លួន ដែលខិតខំប្រឹងប្រែងផ្សព្វផ្សាយអំពីរបៀបរស់នៅដែលនាំឲ្យមានសុខភាពល្អ ដោយពុំចាំបាច់ប្រើគ្រឿងញៀនខុសច្បាប់។

**FAMILY DRUG SUPPORT**
**ការផ្គត់ផ្គង់គ្រួសារដែលមានបញ្ហានឹងគ្រឿងញៀន**

**1300 368 186** (អស់ថ្លៃប្រើទូរស័ព្ទដូចក្នុងតំបន់)

**www.fds.org.au**

គឺជាអង្គការសំរាប់អ្នកទាំងឡាយណាដែលត្រូវការជំនួយ ដើម្បីអ្នកណាម្នាក់ដែលគេស្រឡាញ់។ អង្គការនេះបង្កើតឡើងដោយអ្នកស្ម័គ្រចិត្តដែលមានបទពិសោធន៍ដោយផ្ទាល់ដៃ អំពីការរងប៉ះពាល់ដោយសារសមាជិកគ្រួសារមានបញ្ហានឹងគ្រឿងញៀន។

**BEACON FOUNDATION**

**www.beaconfoundation.net**

Beacon Foundation គឺជាអង្គការជាតិពុំគិតផលប្រយោជន៍ផ្ទាល់ខ្លួន ដែលស្វែងរកដើម្បីបញ្ចូលឥទ្ធិពលលើអាកប្បកិរិយា និងវប្បធម៌របស់ជនជាតិអូស្ត្រាលី ដើម្បីឲ្យមនុស្សវ័យក្មេងម្នាក់ៗបង្កើតនូវបំណងប្រាថ្នាឯករាជ្យ ធ្វើឲ្យបានសម្រេចនូវជោគជ័យសំរាប់ខ្លួនគេផ្ទាល់ និងសហគមន៍របស់គេ។

## KIDSHELP LINE
## (ខ្សែទូរស័ព្ទជំនួយក្មេង)

**1800 551 800** (លេខទូរស័ព្ទឥតគិតថ្លៃ)

**www.kidshelp.com.au**

នេះគឺជាកិច្ចបំរើជាតិផ្តល់ឱវាទតាមទូរស័ព្ទ និងតាមអ៊ីនធើណិតសំរាប់មនុស្សវ័យក្មេងដែលមានអាយុពី៥ឆ្នាំ ទៅ២៥ឆ្នាំ។ កិច្ចបំរើនេះឥតគិតថ្លៃឡើយ អនាមិក ហើយលាក់ការសម្ងាត់ទាំងស្រុង។

## LIFELINE
## (ខ្សែទូរស័ព្ទជួយសង្គ្រោះជីវិត)

**13 11 14** (អស់ថ្លៃប្រើទូរស័ព្ទជួចក្នុងតំបន់)

**www.lifeline.org.au**

នេះគឺជាកិច្ចបំរើជាតិផ្តល់ឱវាទតាមទូរស័ព្ទគ្រប់ពេលម៉ោងទាំងអស់ នៅប្រចាំការដើម្បីជួយលោកអ្នកដោះស្រាយបញ្ហាណាមួយ មិនថាបញ្ហានោះធំ ឬតូចក្តី។

## OXYGEN
## (អុកស៊ីហ៊្សែន)

**www.oxygen.org.au**

OxyGen លើកទឹកចិត្តចំពោះការជ្រើសយករបៀបរស់នៅដែលនាំឲ្យមានសុខភាពល្អ ហើយផ្តល់សកម្មភាព និងពត៌មានឲ្យគ្នាទៅវិញទៅមក អំពីថ្នាំជក់សំរាប់មនុស្សវ័យក្មេង។

## REACH OUT
## (ឈោងចាប់យក)

**www.reachout.com**

គឺជាកន្លែងនៅតាមអ៊ីនធើណិត ដែលលោកអ្នកអាចរកឃើញពត៌មានដែលលោកអ្នកត្រូវការអំពីបញ្ហាសុខភាពផ្លូវចិត្ត និងកន្លែងទំនេរមួយចំនួនសំរាប់បន្ធូរអារម្មណ៍ទាំងស្រុង។ សូមឈោងចាប់យក។ ស្វែងរកឲ្យបានឃើញ។ ចាប់ផ្តើមបន្តទៅមុខទៀត។

## MOODGYM

**www.moodgym.anu.edu.au**

MoodGym គឺជាកម្មវិធីវិបសាយដែលបានកែប្រែតាមរបៀបថ្មីឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលបានរៀបចំឡើងដើម្បីទប់ទល់ និងកាត់បន្ថយរោគសញ្ញានៃការធ្លាក់ទឹកចិត្ត។ កម្មវិធីនេះបានរៀបចំឡើងសំរាប់មនុស្សវ័យក្មេង ក៏ប៉ុន្តែមានប្រយោជន៍សំរាប់មនុស្សគ្រប់វ័យ។

## BEYONDBLUE

**www.beyondblue.org.au**

នេះគឺជាផែនការការផ្តួចផ្តើមជាតិស្តីអំពីជម្ងឺធ្លាក់ទឹកចិត្ត។ ធ្វើឲ្យយើងបានដឹងការពិតអំពីជម្ងឺធ្លាក់ទឹកចិត្តដែលមានពាសពេញក្នុងប្រទេសអូស្ត្រាលី។

## HEADSPACE

**www.headspace.org.au**

Headspace ផ្តល់ការជួយផ្គត់ផ្គង់ផ្នែកសុខភាពផ្លូវចិត្ត និងសុខុមាលភាព ពត៌មាន និងកិច្ចបំរើដល់មនុស្សវ័យក្មេង និងគ្រួសាររបស់គេគ្រប់ទីកន្លែងក្នុងប្រទេសអូស្ត្រាលី។

## NATIONAL RELAY SERVICE
## (កិច្ចបំរើជាតិបញ្ជូនតគ្នា)

លេខទូរស័ព្ទហៅបញ្ជូនតគ្នា TTY/សម្លេង **13 36 77** ធ្វើការគ្រប់ពេលម៉ោងទាំងអស់

និយាយ និងស្តាប់ (SSR) **1300 555 727**

National Relay Service គឺជាកិច្ចបំរើផ្តល់លទ្ធភាពប្រើទូរស័ព្ទពាសពេញប្រទេសអូស្ត្រាលី សំរាប់មនុស្សថ្លង់ ឬអ្នកមានពិការភាពផ្នែកស្តាប់ឮ ឬផ្នែកនិយាយស្តី។

**សូមកុំភ្លេចថា ប្រសិនបើលោកអ្នកប្រើទូរស័ព្ទចល័តដើម្បីហៅលេខដែលមានរាយឈ្មោះខាងលើនេះ លោកអ្នកនឹងត្រូវបង់ថ្លៃហៅដែលគិតតាមតម្លៃទូរស័ព្ទចល័ត។**